ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែសីហា ឆ្នាំ២០១៤

## I- សភាពការណ៍រួម

ក្នុងខែសីហា ឆ្នាំ២០១៤នេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ បានកត់សម្គាល់ឃើញថា បរិមាណទឹកភ្លៀងបានធ្លាក់ជាមធ្យមគ្រប់តំបន់ទូទាំងប្រទេស។ មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន៩០,៥៩ភាគរយ នៃផែនការនិងមានសភាពយឺតជាងឆ្នាំមុន(៤,៩៤ភាគរយ) បើប្រៀបធៀបរយៈពេលដូចគ្នា ហើយខេត្តដែលអនុវត្តបានលឿនជាងគេគឺខេត្តមណ្ឌលគិរី សម្រេចបាន១០៨,៧៨ភាគរយ នៃផែនការ២០.០០០ហិកតា និងខេត្តបន្ទាយមានជ័យអនុវត្តបាន២៤៣.៧២៥ហិកតា ស្មើនឹង១០៣,៧១ភាគរយ នៃផែនការ២៣៥.០០០ហិកតា។ ដោយឡែក ខេត្តមួយចំនួនក៏ទទួលរងនូវការប៉ះពាល់ដោយគ្រោះរាំងស្ងួតនិងគ្រោះទឹកជំនន់ផងដែរ។ ទោះជាយ៉ាងណា ប្រជាកសិករកំពុងបន្តការងារបង្កបង្កើនផលដំណាំរដូវវស្សាយ៉ាងសកម្ម ជាពិសេសខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាបព្រោះ ដក ស្ទូង និងធ្វើកសិកម្មចម្រុះ ដើម្បីឲ្យទាន់រដូវកាលដាំដុះ។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែសីហា ឆ្នាំ២០១៤នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវវស្សាឆ្នាំ២០១៤

-ផ្ទៃដីភ្ជួររាស់សរុបចំនួន២.៥៧៥.៤៨៥ហិកតា (ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីចំនួន៥៤៧.៩០១ហិកតា ស្មើនឹង ២១,២៧% និងគ្រឿងយន្តចំនួន២.០២៧.៥៨៤ហិកតា ស្មើនឹង៧៨,៧៣%) តិចជាងឆ្នាំមុនចំនួន៤១៣.៤៨៨ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន២៣៦.៧៨៩ហិកតា

-ផ្ទៃដីសាបសរុបចំនួន១០៩.១៨៨ហិកតា តិចជាងឆ្នាំមុនចំនួន៤៧.៣៣៨ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៧១.០៤៨ហិកតា

-ផ្ទៃដីស្ទូងនិងពង្រោះសរុបចំនួន២.១៨៤.៣៨០ហិកតា ស្មើនឹង៩០,៥៩ភាគរយនៃផែនការ២.៤១១.២០៧ហិកតា តិចជាងឆ្នាំមុនចំនួន១០៧.៩៦៦ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៤៥.៤៨០ហិកតា រួមមាន៖

- ស្រូវស្រាលចំនួន៥៦០.៤១៦ហិកតា (ក្នុងនោះស្រូវបង្កើនរដូវចំនួន១៦៩.៤២៨ហិកតា) តិចជាងឆ្នាំមុនចំនួន១៩.២០៥ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន២១.០៧១ហិកតា
- ស្រូវកណ្តាលចំនួន១.០៣៩.៤៨៤ហិកតា តិចជាងឆ្នាំមុនចំនួន៤៧.១២១ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន៥០.៣៨២ហិកតា
- ស្រូវធ្ងន់ចំនួន៤៨៤.០៣០ហិកតា តិចជាងឆ្នាំមុនចំនួន២៥.៣៧៩ហិកតា និងលើសមធ្យមភាគច្រើនឆ្នាំចំនួន១០.០០១ហិកតា
- ស្រូវចម្ការចំនួន៤៣.៩៧៧ហិកតា តិចជាងឆ្នាំមុនចំនួន២.៧៧៧ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៤.៦៤៨ហិកតា



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

- ស្រូវឡើងទឹកចំនួន៥២.៤៧៣ហិកតា តិចជាងឆ្នាំមុនចំនួន១៣.៤៨៤ហិកតា និងតិចជាងមធ្យមភាគច្រើនឆ្នាំចំនួន៣១.៣២៧ហិកតា។

**១.២ ដំណាំរួមផ្សំ**

ផ្ទៃដីសម្រេចបានចំនួន៦៣៨.០១៣ហិកតា ស្មើនឹង១២០,៨៣% នៃផែនការចំនួន៥២៨.០១៨ហិកតា លើសឆ្នាំមុនចំនួន៣៦.៦៤៣ហិកតា។

**១.៣ ដំណាំឧស្សាហកម្ម**

ផ្ទៃដីសម្រេចបាន១១៥.៨៤៩ហិកតា ស្មើនឹង៧៣,៨៥% នៃផែនការ១៥៧.០០៧ហិកតា តិចជាងឆ្នាំមុន៩.៣០៣ហិកតា។

**១.៤ ការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៤**

ការងារប្រមូលផលស្រូវស្រាលដើមរដូវសម្រេចបានលើផ្ទៃដីសរុបចំនួន១៣៩.៨៤៥ហិកតា តិចជាងឆ្នាំមុន ២៤.៤៦០ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៥២៤.៤៦០តោន តិចជាងឆ្នាំមុន៨៥.៧៤៥តោន និងទិន្នផលជាមធ្យមចំនួន៣,៧៥០តោនក្នុងមួយហិកតា លើសឆ្នាំមុន៣៦គីឡូក្រាមក្នុងមួយហិកតា។

**១.៥ ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ**

-គ្រោះខ្វះទឹកៈ ប៉ះពាល់លើផ្ទៃដីសរុបចំនួន៩២.១១៣ហិកតា ក្នុងនោះសំណាបសរុបចំនួន៧.៦៤៦ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន៨៤.៤៦៧ហិកតា។ សំណាបខូចខាតអស់ចំនួន១.៨៩៤ហិកតា និងសន្ទូង-ពង្រោះខូចខាតចំនួន៩.៧៤៧ហិកតា(តារាងជូនភ្ជាប់)

-គ្រោះទឹកជំនន់ៈ ប៉ះពាល់លើផ្ទៃដីសរុបចំនួន៧៦.៨៦៤ហិកតា ក្នុងនោះសំណាបសរុបចំនួន២៣៤ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន៧៦.៦៣០ហិកតា។ សំណាបខូចខាតអស់ចំនួន៧០ហិកតា និងសន្ទូង-ពង្រោះខូចខាតចំនួន១៩.៣១៦ហិកតា និងស្តារបានសន្ទូង-ពង្រោះចំនួន២.២៨៨ហិកតា(តារាងជូនភ្ជាប់)។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានដោះស្រាយពូជស្រូវសរុបចំនួន៦០តោន ជូនដល់ខេត្តតាកែវចំនួន៣០តោន និងខេត្តកំពង់ស្ពឺចំនួន៣០តោន ដើម្បីស្តារការខូចខាតឡើងវិញក្រោយទឹកជំនន់។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអភិវឌ្ឍកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបានដល់ខែនេះ (តោន) | បញ្ចេញលក់ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៨៤,៣១ | ៣៤៥,៥៨ | ៣០០,០០ |
| | សរុប I | ៤០៦,៦០ | ៣៨៤,៣១ | ៣៤៥,៥៨ | ៣០០,០០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អិនវេសមេន គ្រុប | ១០.៧១៩,០០ | ៥.៣២៧,០៥ | ៩.៧៩៣,៣១ | ៤.៨២៣,៣២ |
| ២ | ក្រុមហ៊ុន ស៊ីហ្វ៉ាប់ឃើលីមីធីត (រតនគីរី) | ៧៨,៥៣ | ១.៦២៥,៩០ | ៤៥១,៧៩ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៩០ | ៨៨៥,០១ | ៥៥៦,៤៤ | ៣៨៤,៩០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៥៧១,៥២ | ៣.០៥៨,២៧ | ២.៦៦៦,២០ | ២.១៥៥,៩០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.២៥៩,០៨ | ២.២៤៤,៩៨ | ១.៤៦៤,៩៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសសស់ (ស្នួល) | ១.៦២៣,២០ | ២.៧៦៣,០១ | ១.១៣១,៣៦ | ៩៤៦,៩០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០៦៨,០០ | ១.១១៨,៣២ | ៩៥៥,៩០ | ៦៩៥,០០ |

| | | | | | |
|---|---|---|---|---|---|
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្ដូង) | ២.០៣៨,០០ | ៣.៦៣៩,២១ | ៨៤៧,៨៣ | ៦១៥,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.៥៧០,៦៣ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.០៧៧,៩២ | ២.៨៥២,៧៤ | ២.៣៥៨,៤០ |
| សរុប II | | ២៧.០០២,៣៤ | ២៧.៣២៤,៤០ | ២១.៥០០,៤៥ | ១៣.៤៤៣,៦៨ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៨៤.៩០២,០០ | ៣០.៦០៦,០០ | ៣០.៦០៦,០០ |
| សរុប III | | ៦១.២៧១,០០ | ២២០.៣៤៨,០០ | ៣០.៦០៦,០០ | ៣០.៦០៦,០០ |
| សរុប I+II+III | | ៨៨.៦៧៩,៩៤ | ២៤៨.០១៦,៧១ | ៥២.៤៥២,០៣ | ៤៤.៣៤៩,៦៨ |

### ២.២ ការងារស្រាវជ្រាវកៅស៊ូកម្ពុជា

-ចុះប្រមូលទឹកជ័រតាមចម្ការពិសោធន៍នីមួយៗ

-បើកវគ្គបណ្ដុះបណ្ដាលស្ដីពីការកែច្នៃកៅស៊ូ RSS&TSR និងការធ្វើចំណាត់ថ្នាក់ដែលមានអ្នកចូលរួមចំនួន ៥៩នាក់ មកពីខេត្តត្បូងឃ្មុំ កំពង់ចាម ក្រចេះ សៀមរាប ស្វាយរៀង ព្រះវិហារ និងខេត្តរតនគិរី

-រៀបចំថ្នាលបណ្ដុះកូនកៅស៊ូឆ្នាំ២០១៤ និងរៀបចំអត្ថបទស្រាវជ្រាវស្ដីពីជំងឺប្រផេះលើដំណាំកៅស៊ូ

-វាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូនបានចំនួន៣.២០០ដើម របស់ក្រុមហ៊ុនចម្ការកៅស៊ូសុកហ៊ៀនកាសេដ នៅខេត្តមណ្ឌលគិរី

-ដាំពូជ IRCA317 បានចំនួន៣.៣៦២កូន នៅឡូត៍៥៣DSE និងកាត់ខ្មែងបាន៤៣,៧៥ហិកតា

-ធ្វើជំរឿនកូនកៅស៊ូនៅក្នុងឡូត៍ពិសោធន៍ក្លូន SR.AA.01 បានចំនួន២៨៤ដើម និងដាំជួសរួចជាស្ថាពរ។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន៣៧៦ក្បាល ក្នុងនោះជ្រូកបាចំនួន១៣ក្បាល ជ្រូកមេចំនួន១០២ក្បាល និងកូនជ្រូកចំនួន២២៥ក្បាល

-គោសរុបចំនួន១៩១ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦២ក្បាល គោជំទង់ចំនួន៥១ ក្បាល គោបៅដោះចំនួន៣៦ក្បាល និងគោកំផែងសែនចំនួន៣៨ក្បាល។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

-ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី-ពពែ ជំងឺសារទឹកចំនួន៦.៥៨៣ក្បាល និងជំងឺអុតក្ដាមចំនួន៦.៨៣២ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៥.៣២៣ក្បាល ជំងឺប៉េស្ដចំនួន៦.៨៦៣ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៦.៩៤៦ក្បាល ជំងឺអុតក្ដាមចំនួន១៦៥ក្បាល ជំងឺអូហ្សេស្គីចំនួន១.១០៦ក្បាល និងជំងឺកញ្ជ្រឹលចំនួន ១៥០ក្បាល

-ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន១៥.៨៣៩ក្បាល ជំងឺញីវកាសចំនួន៣៣.៧០៨ក្បាល ជំងឺអាសន្នរោគចំនួន២៥.១៥៨ក្បាល និងជំងឺប៉េស្ដទាចំនួន៣១.០០០ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្ដាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្ដជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្ដីពីជំងឺផ្ដាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-បានពិនិត្យវត្ថុវិភាគសរុបចំនួន៩១សំណាក

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន១៥៤ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

-តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅលើទីផ្សាររាជធានី ខេត្តទូទាំងប្រទេស និងទទួលទូរស័ព្ទមកពីតាមបណ្តារាជធានី ខេត្ត សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព របាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺដោយសារជំងឺផ្តាសាយបក្សី

-ធ្វើការឃាត់ចាប់បទល្មើស៦ករណី ដោយឃាត់ចាប់ជ្រូកចំនួន៥១ក្បាល មាន់ចំនួន១.០០០ក្បាល ស៊ុតចំនួន ២១.៩០០គ្រាប់ ដោះលែងចំនួន០១ករណី និងធ្វើការផាកពិន័យជាទឹកប្រាក់ចំនួន១១.៥០០.០០០រៀល

-ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងជ្រូកចំនួន១២លើក មាន់ចំនួន២២លើក ទាចំនួន១១លើក ទ្រុងចិញ្ចឹមចំនួន២លើក បរិវេណភូមិចំនួន៥៨លើក និងសត្តឃាតដ្ឋានចំនួន៣៩លើក

-ចាត់ក្រុមអន្តរាគមន៍ចុះប្រតិបត្តិការជាប្រចាំដើម្បីធ្វើការទប់ស្កាត់ចលនាបក្សី និងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាងដោយខុសច្បាប់ ដោយបានអនុវត្តវិធានការបសុពេទ្យជាក់ស្តែង ព្រមទាំងបានណែនាំប្រជាពលរដ្ឋ និងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជនៈ ឈើហ៊ុបមូលសរុបចំនួន ៩.៦៥០ម៣ ឈើអារចំនួន៣.២២៦ម៣ ឈើជ្រុងចំនួន៦៩ម៣ កូនឈើចំនួន១៥.៦៦៨ដើម និងអុសចម្រុះចំនួន ២.៨៥៩ស្ទែរ ឬស្សីចំនួន ១.៥២៨ដើម ជ័រទឹកចំនួន១៤៥តោន ពកចំនួន៧.២០៥គ.ក្រ ផ្សិតចំនួន៩.៨១២គ.ក្រ សសរចំនួន២៥៥ដើម គ្រាប់ស្លែងចំនួន៥.៣៥៩គ.ក្រ ជន្លង់ម្រេចចំនួន៥.១៦០ដើម ប្រឡៅមូលចំនួន៤៣ដើម បង្គាលគ្រាក់ចំនួន៤២៨ដើម អាកាស្យាចំនួន៣៦០ដើម បង្គាលរបងចំនួន៤៥៣ដើម តុ កៅអី ទ្វារ បង្អួច ទូ គ្រែចំនួន១៤៧គ្រឿង សន្លឹកទ្វារបង្អួចចំនួន១៣២សន្លឹក ក្បាលគ្រែចំនួន២គូ គ្រែចំនួន៣០សម្រាប់ សន្លឹកទ្វារទូចំនួន៥វង់ កៅអីវែងចំនួន៣ កៅអីខ្លីចំនួន៤ ជើងតុចំនួន១ដើម ជើងកៅអីចំនួន៣០គូ គល់ផ្ចង់ចំនួន៤.៧៤៧គ.ក្រ គល់ឈើចំនួន២គល់ ជើងទៀនជណ្តើរចំនួន១ដើម បង្កាន់ដៃជណ្តើរចំនួន៥ដើម គ្រោងឆ្អឹងទ្វារចំនួន៣៥វង់ ចុង្កាចំនួន២៨ចុង និងចម្លាក់ឈើតាក់ប៉ោងចំនួន៤

-រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើត និងគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តពោធិ៍សាត់ចំនួន២៦សហគមន៍ព្រៃឈើ មានផ្ទៃដីសរុបចំនួន៦.៨៨៣ហិកតា

-ពិនិត្យលើសេចក្តីព្រាងផែនការគ្រប់គ្រងព្រៃសហគមន៍នៅខេត្តកំពតចំនួន០២ ខេត្តកំពង់ធំចំនួន០២ និងខេត្តស្ទឹងត្រែងចំនួន០២

-សហគមន៍ព្រៃឈើនៅទូទាំងប្រទេសមានចំនួន៤៧៩សហគមន៍ ដែលអង្គភាពជំនាញកំពុងខិតខំពង្រឹងសហគមន៍ទាំងនោះតាមរយៈការទាក់ទាញជំនួយបច្ចេកទេសពីដៃគូដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍ឲ្យអនុវត្តការធ្វើកសិកម្មចម្រុះបន្ថែមទៀត ដោយមិនអាស្រ័យទៅលើតែផល អនុផលព្រៃឈើ ព្រមទាំងចូលរួមថែរក្សា ការពារព្រៃឈើនៅក្នុងសហគមន៍ប្រកបដោយនិរន្តរភាព។

### ៤.២ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(បឹងព្រែកល្ពៅ តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឺបកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបប្រមាណ២០៧ប្រភេទ ស្មើនឹងជាង៣៥៣ពាន់ក្បាល

-រៀបចំអាហារដ្ឋានត្មាតចំនួន០៣លើក នៅតំបន់អភិរក្សជីវចម្រុះសៀមប៉ាងនិងព្រៃការពារព្រះវិហារ ដោយរាប់ឃើញត្មាតសរុបប្រមាណជិត១៨៥ក្បាល

-ការពារសម្បុកសត្វត្រយ៉ងយក្សចំនួន១៤ក្បាល និងសត្វក្រៀលចំនួន១២ក្បាល នៅព្រៃការពារសៀមប៉ាង និងព្រៃការពារព្រះវិហារ។

### ៤.៣ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន២៧លើក អំពីច្បាប់ស្តីពីព្រៃឈើ ការសន្សំប្រាក់ ផែនការគ្រួសារ ការអភិរក្សនិងទប់ស្កាត់ការកាប់រានដីព្រៃ និងផ្តល់ចំណេះដឹងអំពីបរិស្ថាននិងការអភិរក្សសត្វស្លាប ដែលមានប្រជាជនចូលរួមសរុបចំនួន៥៨៨នាក់ (ស្ត្រីចំនួន២២០នាក់)។

### ៤.៤ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

-ក្នុងខែសីហា ឆ្នាំ២០១៤នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន៨៨ក្បាល សត្វកើតថ្មីចំនួន៣ក្បាល សត្វដោះលែងចំនួន៦៧ក្បាល សត្វស្លាប់ចំនួន១៣ក្បាល ព្យាបាលសត្វចំនួន២៣ក្បាល យកសំណាកទៅពិសោធន៍ចំនួន២៣ក្បាល ធ្វើឲ្យសន្លប់ចំនួន៨៦ក្បាល ទម្លាក់សត្វល្អិតចំនួន១២៤ក្បាល វះកាត់សាកសពសត្វចំនួន៦ក្បាល ដាក់លេខកូដចំនួន៧ក្បាល សាងសង់របងហ៊ុំព័ទ្ធនិងទ្រុងសត្វថ្មីលើចំនួន៨៣៣ម$^2$ ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន១៨ម$^2$ ជួសជុលផ្លូវចំនួន៤.៩៧៥ម$^2$ ថ្មារអនាម័យព្រៃចំនួន២២.៧០០ម$^2$ ដាំកូនឈើចំនួន៧៨៧ដើម បណ្តុះផ្កាលម្អចំនួន៧២៤ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន៥.១៩៦នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមមេ-បាពូជ និងកូនស្វាក្តាមចំនួន៥២.៣៧១ក្បាល។

### ៤.៥ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

-កូនក្រពើចំនួន២២ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង ត្រូវបាននាំយកទៅថែរក្សាបណ្តោះអាសន្ននៅតំបន់អារ៉ែង ឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង ដើម្បីដោះលែងចូលបឹងធម្មជាតិនៅចុងខែសីហា ឆ្នាំ២០១៤

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល តំបន់ស្ពានក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេង

-ចុះស្រាវជ្រាវចម្ការពូជឈើធ្នង់ កកោះ និងបេង នៅសហគមន៍នាងកង្រី ខេត្តកំពង់ឆ្នាំង និងសហការប្រមូលគ្រាប់ពូជជាមួយសហគមន៍ ដើម្បីយកមកប្រើប្រាស់បណ្តុះកូនឈើរបស់គម្រោងដាំឈើប្រចាំឆ្នាំ២០១៥

-រៀបចំដាំជាចម្ការពូជឈើប្រភេទដូនចែមចំនួន០៥ហិកតា នៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

-បន្តស្រាវជ្រាវពូជឈើមានដោយកម្រនៅក្នុងតំបន់សហគមន៍ព្រៃឈើនានាសម្រាប់ទិសដៅប្រើប្រាស់គ្រាប់ពូជ។

### ៤.៦ ការងារដាំដើមឈើ

-ការដាំឈើក្នុងពិធីបុណ្យរុក្ខទិវា ការដាំឈើជាចម្ការនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើរបស់រដ្ឋ ក្រុមហ៊ុនឯកជន ក្រុមហ៊ុនដៃគូជាមួយរដ្ឋបាលព្រៃឈើ ផ្នែកឯកជនខ្នាតតូច/ធំ និងអង្គការក្រៅរដ្ឋាភិបាល និងការថែទាំចម្ការឈើចាស់ បានឈូសឆាយដីព្រៃសរុបចំនួន១៥០ហិកតា ដាំឈើជាចម្ការបានចំនួន១.៧៤៨ហិកតា បណ្តុះកូនឈើគ្រប់ប្រភេទចំនួន៧២៩.៨៣៤ដើម និងចែកចាយកូនឈើគ្រប់ប្រភេទចំនួន២.០៦៧.៤៧៣ដើម។

### ៤.៧ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

-ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឬស្សីអាកាសស្យាជូនក្រុមហ៊ុនចំនួន៣២គោន

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន០១ ស្មើនឹង៦ច្បាប់ ដែលមានបរិមាណឈើកែច្នៃចំនួន៩៧៨,៧៧៦ម$^3$

-ផ្តល់គោលការណ៍ឲ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន១កន្លែង ព្រមទាំងបានផ្តល់លិខិតបង្កើតរោងសិប្បកម្មធុនតូចចំនួន១៥សន្លឹក និងរោងសន្និធិចំនួន១៦សន្លឹក។

## ៤.៨ ការងារចំណូលព្រៃឈើ

-ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន១.២១២.៤២០.៧៨៧រៀល និងផ្តល់សេវាសាធារណៈចំនួន ១១.២៤០,៥៦ដុល្លារ និង៦១៦.២៤០.៣២០រៀល។

## ៤.៩ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់ឆកទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានទូទាំងប្រទេសសរុបចំនួន២៩៨ករណី ដោយបញ្ជូនទៅតុលាការសរុបចំនួន២៣៨ករណី និងពិន័យអន្តរការណ៍ចំនួន ៦០ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១៦៧ម៣ ឈើអារចំនួន៨៤៩ម៣ ឈើក្រាក់គ្រញូងចំនួន៦ម៣និង៣.៤៩៥គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដកហូតដីព្រៃឈើចំនួន៩.៥២២ហិកតា

-ស្ថិតដីព្រៃទទួលរងការកាប់រានសរុបចំនួន២២ហិកតា និងបានបង្ក្រាបការកាប់រានដីព្រៃឈើសរុបចំនួន៣៦ហិកតា

-បង្ក្រាបនិងដកហូតរណារយន្តកាត់-អារឈើសរុបចំនួន០៧គ្រឿង។

# ៥ វិស័យជលផល

## ៥.១ ការនេសាទ

### ៥.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន២៤.០០០តោន ស្មើ១៦០% នៃផែនការ ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១១.០០០តោន(បញ្ចប់រដូវ)

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ ក្នុងខែចំនួន១៥.០០០តោន សរុបបានចំនួន២០៥.០០០តោន ស្មើ៥២,៥៦% នៃផែនការ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤៥.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ ក្នុងខែចំនួន១០.០០០តោន សរុបបានចំនួន៧៥.០០០តោន ស្មើ៤១,៦៧% នៃផែនការ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន។

### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៤

-អនុវត្តក្នុងខែចំនួន៩.០០០តោន សរុបចំនួន៧០.០០០តោន ស្មើ៦៣,៦៤% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤.០០០តោន។

## ៥.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែចំនួន៨.០០០តោន សរុបបានចំនួន៦៥.០០០តោន ស្មើ៦៥% នៃផែនការ ១០០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧.០០០តោន

-ការចិញ្ចឹមក្រពើ ក្នុងខែចំនួន១០.០០០ក្បាល សរុបបានចំនួន២០០.០០០ក្បាល ស្មើ៦៦,៦៧% នៃផែនការ ៣០០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ ក្នុងខែចំនួនប្រមាណ៣០.០០០.០០០កូន សរុបបានចំនួនប្រមាណ១៥០.០០០.០០០កូន ស្មើ ៨៣,៣៣% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួនប្រមាណ៦០.០០០.០០០កូន។

## ៥.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ ក្នុងខែចំនួន៥.០០០តោន សរុបបានចំនួន៤៧.០០០ តោន ស្មើ៣១,៣៣% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ ក្នុងខែចំនួន៤០០តោន សរុបបានចំនួន៦.២០០តោន ស្មើ៧៧,៥០% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧០០តោន

-ការផលិតទឹកត្រី ក្នុងខែចំនួន៤.០០០.០០០លីត្រ សរុបបានចំនួន៥២.០០០.០០០លីត្រ ស្មើ៨៦,៦៧% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៩.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ ក្នុងខែចំនួន១.២០០តោន សរុបបានចំនួន៧.៧០០តោន ស្មើ៣៨,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០០តោន

-ផលនេសាទកែច្នៃ ក្នុងខែចំនួន៨០០តោន សរុបបានចំនួន៤.១០០តោន ស្មើ៤១% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

-កំណត់ហេតុបទល្មើស សរុបចំនួន១.២១៥ករណី ដែលកើតមាននៅតំបន់ទឹកសាប១.១៦២ករណី និងតំបន់សមុទ្រ៥៣ករណី ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥៥៦ករណី គឺតំបន់ទឹកសាបថយចុះ៥៤៨ករណីនិងតំបន់សមុទ្រថយចុះ៨ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលចំណូល

-ចំណូលពីវិស័យជលផល ក្នុងខែចំនួន៣៩៤.៧៦៧.៧០០រៀល សរុបបានចំនួន២.៤៩០.៩២០.៧៣២រៀល ស្មើ៨១,៨៧% នៃផែនការ៣.០៤២.៥០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៩០៣.៣១៦.១៤១រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចុះប្រមូលព័ត៌មានអំពីជីវភាពរស់នៅរបស់ប្រជានេសាទនៅខេត្តតាកែវ ព្រៃវែង និងខេត្តស្វាយរៀង

-ចុះត្រួតពិនិត្យការងារពិសោធន៍ស្រាវជ្រាវនៅស្ថានីយ៍កោះកេរ្តិ៍ ខេត្តព្រះវិហារ

-ជ្រើសរើសទីតាំងនិងពិនិត្យតាមដានមើលការងារពិសោធន៍នៅខេត្តតាកែវ កំពង់ធំ បាត់ដំបង សៀមរាប ព្រៃវែង និងខេត្តកំពង់ឆ្នាំង

-ចុះធ្វើការប្រមូលទិន្នន័យស្ដីពីការទទួលយកពូជស្រូវទាំង១០របស់កសិករនិងប្រមូលពូជដំណាំយកមើមនៅខេត្តកំពង់ចាម និងខេត្តព្រៃវែង

-ចុះធ្វើទិវាស្រែបង្ហាញរបស់គម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ចនៅស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ចំនួន០៣កន្លែង ដែលមានអ្នកចូលរួមសរុបចំនួន៣៤៥នាក់

-ចុះធ្វើការអនុវត្តបង្ហាញពីបច្ចេកទេសនៃការប្រើប្រាស់ម៉ាស៊ីន ដាំគ្រាប់ស្រូវនៅខេត្តតាកែវ ដែលមានអ្នកចូលរួមសរុបចំនួន២៣នាក់

-ចុះពិនិត្យ ពិភាក្សាការងារជាមួយដៃគូសហការលើការងារក្រោយពេលប្រមូលផលនៅខេត្តតាកែវ និងវាយតម្លៃការងារពិសោធន៍ពូជស្រូវធន់ទ្រាំនិងជាតិប្រៃនៅតំបន់ឆ្នេរសមុទ្រ ខេត្តកោះកុង។

## ៧ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៣៨៩ច្បាប់ សរុបចំនួន៣.៦៨៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទក្នុងខែចំនួន៤១៦ច្បាប់ សរុបចំនួន២.៩១៦ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១៥៤ច្បាប់ សរុបចំនួន៩៤៧ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៦២៣ច្បាប់ សរុបចំនួន៥.៦៨០ច្បាប់ ប្រកាស សេចក្ដីសម្រេច និងសារាចរ ក្នុងខែចំនួន៨៣ច្បាប់ សរុបចំនួន៤២៦ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន១៨ច្បាប់ សរុបចំនួន៤៧៥ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៨ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

-រៀបចំនិងដំណើរការវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងគម្រោងតាមប្រព័ន្ធ Database ជូនមន្ត្រីជំនាញក្រោមឱវាទក្រសួងចំនួន៤៦នាក់ នៅខេត្តសៀមរាប

-ចូលរួមកិច្ចប្រជុំពិសេសលើកទី៣៥ របស់ឧត្តមមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន កិច្ចប្រជុំពិសេសលើកទី១៣ របស់ឧត្តមមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ានបូក៣ និងប្រជុំឧត្តមមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន សហព័ន្ធរុស្ស៊ីលើកទី១ ព្រមទាំងកិច្ចប្រជុំពាក់ព័ន្ធនានា

-រៀបចំលិខិតអន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីកែសម្រួលសេចក្តីព្រាង MOU on Cooperation in Agriculture and Related រវាងកម្ពុជា-ស៊ីរីស្តុល

-រៀបចំលិខិតអន្តរាគមន៍ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីប្រើប្រាស់ជំនួយឥណ្ឌាក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា

-ចូលរួមត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពនៃការអនុវត្តគម្រោងរបស់អង្គការជាដៃគូដែលបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-សម្របសម្រួលរៀបចំបែបបទ និងគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង ទីប្រឹក្សាបច្ចេកទេស និងមន្ត្រីរាជការក្រោមឱវាទដូចជាលិខិតឆ្លងដែន ពន្យារទិដ្ឋាការស្នាក់នៅ ព្រមទាំងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាបានចំនួន៨០រូប នៅក្នុងប្រទេសចំនួន១៣។

## ៩ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

ក្របខណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៦៨៦នាក់ នារីចំនួន១.២៧៧នាក់ ស្មើនឹង១៩% រួមមាន៖

-អង្គភាពថ្នាក់កណ្តាលចំនួន៤.០៨៤នាក់ ក្នុងនោះនារីចំនួន៧៤៥នាក់ ស្មើនឹង១៨,២៤%

-អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦០២នាក់ ក្នុងនោះនារីចំនួន៥៣២នាក់ ស្មើនឹង២០,៤៤%

-ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន៨នាក់ និងក្នុងប្រទេសចំនួន១០នាក់

-រៀបចំធ្វើអត្តសញ្ញាណប័ណ្ណមន្ត្រីរាជការក្របខណ្ឌថ្មី និងបានរៀបចំធ្វើនិយតកម្មដល់មន្ត្រីរាជការថ្នាក់កណ្តាល និងរាជធានី ខេត្ត

-ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ១០ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.៥២៤នាក់(ស្រី៤៩៧នាក់) ក្នុងនោះមាននិស្សិតអាហារូបករណ៍ និស្សិតបង់ថ្លៃ និងនិស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យ ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សាលាជាតិកសិកម្មព្រែកលៀបបានរៀបចំការការពារសារណាសម្រាប់និស្សិតសរុបចំនួន៤០៣នាក់(នារី១២៨នាក់)លើមុខជំនាញចំនួន៩ និងប្រជុំរៀបចំកម្មវិធីសិក្សាថ្មី២០១៤-២០១៥ ព្រមទាំងសិក្សាអំពីលទ្ធភាពកាត់បន្ថយចំនួនម៉ោងនិងក្រេឌីតក្នុងក្របខណ្ឌកំណែទម្រង់។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់) រួមមាន៖

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់(ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន ១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផលដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់ (ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ។ មន្ត្រីសាស្ត្រាចារ្យទាំងក្នុងនិងក្រៅបានខិតខំយកចិត្តទុកដាក់ធ្វើការអភិវឌ្ឍនូវមុខជំនាញបច្ចេកទេសរបស់ខ្លួន ពិសេសអភិវឌ្ឍសម្ភារបច្ចេកទេសបង្រៀនឲ្យកាន់តែប្រសើរឡើង និងធ្វើការសិក្សាស្រាវជ្រាវសំដៅលើកកម្ពស់គុណភាពសិក្សា និងចូលរួមគ្រប់សកម្មភាពទាំងការងាររៀននិងបង្រៀន។ ដឹកនាំនិស្សិតចុះធ្វើការអនុវត្តជាក់ស្តែងនៅខេត្ត ក្រុងនានា និងតាមទីវាល ជាពិសេសបានចូលរួមធ្វើកម្មសិក្សាអនុវត្តការងារជាក់ស្តែងរួមជាមួយនិស្សិតបរទេស រួមមាននិស្សិតមកពីសាកលវិទ្យាល័យឈុនណាម សាកលវិទ្យាល័យស្ត្រីដុកស៊ុង ប្រទេសកូរ៉េ និងសាកលវិទ្យាល័យប្រាក ប្រទេសឆេក។ សាកលវិទ្យាល័យមានទំនាក់ទំនងជាមួយសាកលវិទ្យាល័យ វិទ្យាស្ថាន អង្គការអន្តរជាតិក្នុងតំបន់និងលើពិភពលោកចំនួន៥៥ សហការលើការអភិវឌ្ឍន៍ចំណេះដឹង ក៏ដូចជាការផ្តល់មូលនិធិសម្រាប់ការសិក្សាស្រាវជ្រាវ និងធ្វើការផ្លាស់ប្តូរនិស្សិត ព្រមទាំងបានធ្វើការបណ្តុះបណ្តាលមន្ត្រី សាស្ត្រាចារ្យនៅក្នុងប្រទេសចំនួន០៦លើក សិក្ខាសាលាចំនួន០៥លើក សន្និសីទចំនួន០១លើក និងបណ្តុះបណ្តាលក្រៅប្រទេសចំនួន ០៣លើក។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៤ ត្រូវបានកត់សម្គាល់ឃើញថា បរិមាណទឹកភ្លៀងបានធ្លាក់ជាមធ្យមគ្រប់តំបន់ទូទាំងប្រទេស។ មកទល់ពេលនេះ ល្បឿនការងារដាំដុះដំណាំស្រូវសម្រេចបាន៩០,៥៩ ភាគរយ នៃផែនការនិងមានសភាពយឺតជាងឆ្នាំមុន(៤,៩៤ភាគរយ) បើប្រៀបធៀបរយៈពេលដូចគ្នា ហើយខេត្តដែលអនុវត្តបានលឿនជាងគេគឺខេត្តមណ្ឌលគិរី សម្រេចបាន១០៨,៧៨ភាគរយ នៃផែនការ២០.០០០ហិកតា និងខេត្តបន្ទាយមានជ័យអនុវត្តបាន២៤៣.៧២៥ហិកតា ស្មើនឹង១០៣,៧១ភាគរយ នៃផែនការ២៣៥.០០០ហិកតា។ ជាមួយនេះប្រជាកសិករកំពុងបន្តការងារបង្កបង្កើនផលដំណាំរដូវវស្សាយ៉ាងសកម្ម ជាពិសេសខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាបព្រោះ ដក ស្ទូង និងធ្វើកសិកម្មចម្រុះ ដើម្បីឲ្យទាន់រដូវកាលដាំដុះ។ រីឯការខូចខាតដោយគ្រោះធម្មជាតិមកទល់ពេលនេះអាចវាយតម្លៃជារួមប្រមាណ១,៣៣ភាគរយ នៃផ្ទៃដីអនុវត្តបាន។ ទោះជាយ៉ាងណា ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងអាជ្ញាធរខេត្តបានត្រៀមបម្រុងនូវស្រូវពូជមួយចំនួនដើម្បីជួយដល់ប្រជាកសិករពេលជួបគ្រោះធម្មជាតិ និងត្រៀមរៀបចំធ្វើថ្នាលសំណាបរួមក៏ដូចជាវិធានការអប់រំដល់ប្រជាកសិករឲ្យត្រៀមបម្រុងទុកស្រូវពូជឲ្យមាននៅក្នុងដៃ ព្រមទាំងចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ ដោយបានចាត់ក្រុមការងារចុះណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ឲ្យចុះជាប្រចាំដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ នៅមុននិងក្នុងពេលជម្លៀសទៅកាន់ទីទួលមានសុវត្ថិភាព និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ក្នុងស្ថានភាពនេះ ក្រសួងក៏បានណែនាំដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត បន្តវាយតម្លៃលើផលប៉ះពាល់ ក៏ដូចជាការខូចខាតលើផលដំណាំ ជាពិសេសជួយអន្តរាគមន៍ស្តារឡើងវិញ

លើផលដំណាំដែលប៉ះពាល់ខូចខាតដោយគ្រោះទឹកជំនន់ និងគ្រោះខ្វះទឹក ដោយបានសហការជាមួយអាជ្ញាធរមូលដ្ឋាន មន្ទីរពាក់ព័ន្ធចុះជួយបូមបាចនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពតាមជាក់ស្តែង។

ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការត្រូវតែខិតខំបន្តសកម្មភាពដូចភ្លៀងរលឹម ជាមួយនឹងការបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមាន។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគាំទ្រផ្សេងៗក៏បានសម្រេចនូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរ ស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## V- ទិសដៅអនុវត្តបន្ត

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតដាយចាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

-តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយដាយចាហេតុ ដើម្បីទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ បន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូនៃការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-ត្រៀមធ្វើការដាំដុះសាកល្បងកូនកៅស៊ូប្រភេទ "Invitro"

-បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំកសាងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីវិស័យព្រៃឈើតាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្លាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្កា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទដូចភ្លៀងរលឹម

-ទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម

-ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារ

បច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រឹកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

-ត្រៀមចូលរួមកិច្ចប្រជុំលើកទី៣៦ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន នៅប្រទេសភូមា ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀត

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងរៀបចំការប្រឡងប្រជែងប្តូរប្រភេទក្របខ័ណ្ឌមន្ត្រីរាជការក្រោមឱវាទ

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
នាយកដ្ឋានផែនការ និង ស្ថិតិ

# ស្ថានភាពផ្ទៃដីប៉ះពាល់និងខូចខាតស្រូវវស្សាឆ្នាំ ២០១៤

(គិតត្រឹមថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៤)

| រាជធានី ខេត្ត | ផ្ទៃដី អនុវត្ត (ហ.ត) | ប៉ះពាល់ (ហ.ត) កង្វះខាតទឹក | | សត្វល្អិត | | ទឹកជំនន់ | | សរុប ប៉ះពាល់ (ហ.ត) | | ខូចខាត (ហ.ត) កង្វះខាតទឹក | | សត្វល្អិត | | ទឹកជំនន់ | | សរុប ខូចខាត (ហ.ត) | | ផ្ទៃដីស្តារឡើងវិញ (ហ.ត) | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| បន្ទាយមានជ័យ | 243,725 | | | | | | | - | - | | | | | | | - | - | | |
| បាត់ដំបង | 246,782 | - | 37,393 | | | - | 800 | - | 38,193 | - | 5,623 | | | - | - | - | 5,623 | - | 1,666 |
| កំពង់ចាម | 80,421 | | | | | 23 | 7,402 | 23 | 7,402 | | | | | 23 | 2,158 | 23 | 2,158 | - | - |
| កំពង់ឆ្នាំង | 99,482 | | | | | - | 353 | - | 353 | | | | | - | 263 | - | 263 | - | - |
| កំពង់ស្ពឺ | 27,191 | 5,966 | 4,399 | | | | | 5,966 | 4,399 | 1,671 | 290 | | | | | 1,671 | 290 | - | - |
| កំពង់ធំ | 208,897 | | | | | - | 9,690 | - | 9,690 | | | | | - | 630 | - | 630 | - | - |
| កំពត | 82,839 | | | | | | | - | - | | | | | | | - | - | | |
| កណ្តាល | 27,450 | 535 | 804 | | | - | 3,563 | 535 | 4,367 | - | - | | | - | 837 | - | 837 | - | - |
| កោះកុង | 10,126 | | | | | | | - | - | | | | | | | - | - | | |
| ក្រចេះ | 31,906 | | | | | 33 | 6,763 | 33 | 6,763 | | | | | 21 | 3,152 | 21 | 3,152 | - | 2,108 |
| មណ្ឌលគិរី | 21,756 | | | | | 150 | 1,100 | 150 | 1,100 | | | | | - | 465 | - | 465 | - | - |
| ភ្នំពេញ | 8,859 | 227 | 627 | | | | | 227 | 627 | 6 | 3 | | | | | 6 | 3 | | |
| ព្រះវិហារ | 72,230 | | | | | - | 6,741 | - | 6,741 | | | | | - | 2,784 | - | 2,784 | - | - |
| ព្រៃវែង | 241,343 | | | | | - | 30,496 | - | 30,496 | | | | | - | 5,199 | - | 5,199 | - | - |
| ពោធិ៍សាត់ | 103,170 | - | 4,785 | | | | | - | 4,785 | - | 2,610 | | | | | - | 2,610 | - | - |
| រតនគិរី | 25,925 | | | | | | | - | - | | | | | | | - | - | | |
| សៀមរាប | 182,755 | | | | | | | - | - | | | | | | | - | - | | |
| ព្រះសីហនុ | 15,949 | | | | | | | - | - | | | | | | | - | - | | |
| ស្ទឹងត្រែង | 27,851 | | | | | - | 4,471 | - | 4,471 | | | | | - | 2,604 | - | 2,604 | - | 28 |
| ស្វាយរៀង | 144,316 | - | 4,100 | | | - | 2,403 | - | 6,503 | - | - | | | - | 152 | - | 152 | - | 152 |
| តាកែវ | 129,687 | 918 | 27,323 | | | - | 139 | 918 | 27,462 | 217 | 746 | | | - | - | 217 | 746 | - | - |
| ឧត្តរមានជ័យ | 69,170 | - | 5,036 | | | - | 165 | - | 5,201 | - | 475 | | | - | - | - | 475 | - | - |
| កែប | 3,240 | | | | | | | - | - | | | | | | | - | - | | |
| ប៉ៃលិន | 6,497 | | | | | | | - | - | | | | | | | - | - | | |
| ត្បូងឃ្មុំ | 72,813 | | | | | 28 | 2,544 | 28 | 2,544 | | | | | 26 | 1,072 | 26 | 1,072 | - | - |
| សរុប | 2,184,380 | 7,646 | 84,467 | - | - | 234 | 76,630 | 7,880 | 161,097 | 1,894 | 9,747 | - | - | 70 | 19,316 | 1,964 | 29,063 | - | 3,954 |

បានឃើញនិងឯកភាព
ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ

ភ្នំពេញ, ថ្ងៃទី ២៧ ខែសីហា ឆ្នាំ២០១៤
ប្រធានការិយាល័យស្ថិតិ